ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាព
# គោលនយោបាយស្តីពីគ្រូបង្រៀន
# ឆ្នាំ២០២៤-២០៣០

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

២០២៣

# មាតិកា


មាតិកា ........ 1
បុព្វកថា ........ 2
ពាក្យកាត់ និងអក្សរកាត់ ........ 4
១. សារបាន ........ 5
១.១. គោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ និងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥ ........ 5
១.២. ស្ថានភាព និងបញ្ហាអាទិភាព ........ 6
២. យុទ្ធសាស្រ្តទាំង៤នៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ និងយុទ្ធសាស្រ្តទាំង៩ នៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ ........ 7
២.១. យុទ្ធសាស្រ្តទាំង៤ ........ 7
២.២. យុទ្ធសាស្រ្តទាំង៩នៃគោលនយោបាយស្តីពីគ្រូបង្រៀន ........ 9
៣. តារាងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ........ 11
៤. ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ........ 52
៤.១. គណៈកម្មការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ........ 52
៤.២. យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ........ 52
៤.៣. ពេលវេលាត្រួតពិនិត្យតាមដាន និងវាយតម្លៃ ........ 52
៥. សទ្ទានុក្រម ........ 54
៦. ឯកសារយោង ........ 55

## បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៣ និងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៥។ នៅឆ្នាំ២០២២ ក្រសួងអប់រំ យុវជន និងកីឡា ក្រោមការគាំទ្ររបស់អង្គការយូនីសេហ្វ តាមរយៈមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ បានរៀបចំពិនិត្យឡើងវិញនូវផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០ និងអភិវឌ្ឍផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ដោយបញ្ចូលនូវលទ្ធផលការពិនិត្យពាក់កណ្តាលអាណត្តិផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនដែលធ្វើឡើងនៅឆ្នាំ២០១៧ ការពិនិត្យឡើងវិញកំណែទម្រង់គ្រូបង្រៀននៃក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៨ និងអនុសាសន៍ស្តីពីការពិនិត្យផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៩។

ការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ គឺជាគន្លឹះក្នុងការកសាងមូលធនមនុស្សដ៏រឹងមាំសម្រាប់បរិវត្តកម្មប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ គ្រូបង្រៀនដែលមានចំណេះដឹង ជំនាញ និងសីលធម៌វិជ្ជាជីវៈ គឺជាតម្រូវការចាំបាច់មិនអាចខ្វះបានដើម្បីសម្រេចគោលដៅនេះ។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ បានផ្តល់មូលដ្ឋានដ៏រឹងមាំក្នុងការរៀបចំផែនទីបង្ហាញផ្លូវរយៈពេលវែងជាក់លាក់ក្នុងការអភិវឌ្ឍគ្រូបង្រៀននៅកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់តួនាទីដ៏សំខាន់របស់គ្រូបង្រៀន និងការបង្រៀនដែលបានជួយដល់ការរៀនប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត។ គ្រូបង្រៀន និងគ្រូឧទ្ទេសត្រូវមានឧត្តមភាពវិជ្ជាជីវៈ ការជ្រើសរើសគ្រូបង្រៀនស្របតាមតម្រូវការ ទទួលបានការបណ្តុះបណ្តាលល្អ មានសមត្ថភាពវិជ្ជាជីវៈ មានការលើកទឹកចិត្ត និងមានការគាំទ្រនៅក្នុងប្រព័ន្ធអប់រំប្រកបដោយធនធានគ្រប់គ្រាន់ និងប្រសិទ្ធភាព។

ការផ្គត់ផ្គង់គ្រូបង្រៀនប្រកបដោយនិរន្តរភាព ទាមទារឱ្យមានការអភិវឌ្ឍគ្រូបង្រៀនតាមបរិបទជាក់ស្តែង និងផ្អែកលើភស្តុតាងដោយមានកិច្ចសហប្រតិបត្តិការពេញលេញពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ គោលដៅ និងការកែលម្អវិស័យអប់រំនៅប្រទេសកម្ពុជាមិនអាចសម្រេចបាន ប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីគ្រូបង្រៀន និងអ្នកអប់រំក្នុងរយៈពេលវែង និងការផ្លាស់ប្តូរដែលសមស្របនឹងសង្គម។ ប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស និងប្រព័ន្ធអប់រំពឹងផ្អែកលើការលើកទឹកចិត្ត សមត្ថភាព និងស្មារតីទទួលខុសត្រូវវិជ្ជាជីវៈរបស់គ្រូបង្រៀន។

ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ផ្តល់នូវការអភិវឌ្ឍនិងបរិវត្តកម្មគំនិត និងយុទ្ធសាស្ត្រច្នៃប្រឌិតក្នុងការធ្វើបរិវត្តកម្មការអប់រំ និងការអភិវឌ្ឍគ្រូបង្រៀន ដែលនឹងលើកកម្ពស់គុណភាពបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សាដោយផ្អែកលើយុទ្ធសាស្ត្រចំនួន៤ ដូចខាងក្រោម៖

- ការគ្រប់គ្រងគ្រូបង្រៀន
- បរិវត្តកម្មភាពជាអ្នកដឹកនាំ
- ការអប់រំគ្រូបង្រៀន
- អត្តសញ្ញាណនិងការអភិវឌ្ឍគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះគណៈកម្មការអភិវឌ្ឍន៍ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ក្រុមការងារវិស័យអប់រំជាពិសេសសហភាពអឺរ៉ុប អង្គការយូនីសេហ្វ អង្គការយូណេស្កូ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍ

អន្តរជាតិអង្គការវីអូប៊ី និងអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដែលបានចូលរួមក្នុងការអភិវឌ្ឍផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០។

ផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ គឺជាផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់កំណែទម្រង់វិស័យអប់រំ និងការអភិវឌ្ឍគ្រូបង្រៀនដ៏ទូលំទូលាយមួយដែលនឹងត្រូវអនុវត្តដើម្បីការអប់រំប្រកបដោយគុណភាព និងសក្ដានុពល។

ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## ពាក្យកាត់ និងអក្សរកាត់

| | |
|---|---|
| ការិ. អយក | ការិយាល័យអប់រំ យុវជន និងកីឡា |
| គអគ | គ្រឹះស្ថានអប់រំគ្រូបង្រៀន |
| គទក | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា |
| នា.គប | នាយកដ្ឋានគោលនយោបាយ |
| នា.ធគអ | នាយកដ្ឋានធានាគុណភាពអប់រំ |
| នា.នត | នាយកដ្ឋាននីតិកម្ម |
| នា.បល | នាយកដ្ឋានបុគ្គលិក |
| នា.បវ | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| នា.បវព | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| នា.បស | នាយកដ្ឋានបឋមសិក្សា |
| នា.ផក | នាយកដ្ឋានផែនការ |
| នា.ពអ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| នា.មចទ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| នា.អកត | នាយកដ្ឋានអប់រំកុមារតូច |
| នា.អកស | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| នា. អពស | នាយកដ្ឋានអប់រំពិសេស |
| មគភ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| មសគជថ | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី |
| មន្ទីរ អយក | មន្ទីរអប់រំ យុវជន និងកីឡា |
| មសគជថ | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី |
| វគ | វិទ្យាស្ថានគរុកោសល្យ |
| វគប | វិទ្យាស្ថានគរុកោសល្យបាត់ដំបង |
| វគភ | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| វជអ | វិទ្យាស្ថានជាតិអប់រំ |
| វជអព | វិទ្យាស្ថានជាតិអប់រំពិសេស |
| សគមម | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| សគវ | សាលាគរុកោសល្យ និងវិក្រឹតការ |
| អគ.អរ | អគ្គនាយកដ្ឋានអប់រំ |
| អគ.រហ | អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |

## ១. សារថាន

### ១.១. គោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ និងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥

គោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ បានកំណត់វិធីសាស្ត្រក្នុងការអភិវឌ្ឍគ្រូបង្រៀនប្រកបដោយគុណភាព សមត្ថភាព និងគណនេយ្យភាព ស្របតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ក៏ដូចជាផ្តល់ឱ្យគ្រូបង្រៀននូវបរិយាកាសការងារប្រកបដោយភាពជោគជ័យ ប្រសិទ្ធភាព និងការទទួលស្គាល់ពីសង្គម។ គោលដៅសំខាន់ៗរួមមាន៖

- ទាក់ទាញ និងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន
- ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន
- ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ
- ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០ ត្រូវបានរៀបចំឡើង និងអនុវត្តនៅឆ្នាំ២០១៥។ ការពិនិត្យឡើងវិញនៃផែនការសកម្មភាពនេះត្រូវបានធ្វើឡើងនៅឆ្នាំ២០១៩ ដោយបានបង្ហាញពីបច្ចុប្បន្នភាពនៃវឌ្ឍនភាពផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០ និងបានផ្តល់នូវទិដ្ឋភាពទូទៅរួមជាមួយនឹងអនុសាសន៍។

ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនត្រូវបានពិនិត្យឡើងវិញចុងក្រោយនៅឆ្នាំ២០២២ ដែលជាចំណុចចាប់ផ្តើមឈានទៅដល់ ការអភិវឌ្ឍផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០។ ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ត្រូវបានអភិវឌ្ឍផ្អែកលើសកម្មភាពពុំទាន់បានអនុវត្តនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០ អនុសាសន៍នៃការពិនិត្យឡើងវិញផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៩ ដែលពុំទាន់បានដោះស្រាយ ការវិភាគឯកសារគោលនយោបាយ ផែនការសកម្មភាព និងក្របខណ្ឌនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ការវិភាគឯកសារគោលនយោបាយគ្រូបង្រៀនដែលជាឧត្តមានុវត្តន៍ផ្អែកលើភស្តុតាង និងគំនិតផ្តួចផ្តើមនានាដែលបានលើកឡើងនៅក្នុងសិក្ខាសាលាកំណត់អាទិភាព និងពិគ្រោះយោបល់ស្តីពីផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ដែលមានការចូលរួមពីគណៈកម្មការអភិវឌ្ឍផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ដៃគូអភិវឌ្ឍន៍ និងក្រុមការងារវិស័យអប់រំ។ យោងតាមលទ្ធផលនៃសិក្ខាសាលាខាងលើ យុទ្ធសាស្ត្រទាំង៩នៃគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ ត្រូវបានបង្រួមទៅជាយុទ្ធសាស្ត្រធំៗចំនួន៤ ដែលត្រូវបានបន្សុីជាមួយយុទ្ធសាស្ត្រនៃគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ និងផ្នែកសំខាន់ៗទាំង៤នៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០។

| យុទ្ធសាស្ត្រនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ឆ្នាំ២០២៤-២០៣០ | យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ | ផ្នែកសំខាន់ៗនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ឆ្នាំ២០១៥-២០២០ |
|---|---|---|
| **១. ការគ្រប់គ្រងគ្រូបង្រៀន** | - កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ<br>- ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន<br>- ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា | - បរិស្ថានសាលារៀន (អធិការកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សៀវភៅសិក្សា) |
| **២. បរិវត្តកម្មភាពជាអ្នកដឹកនាំ** | - ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន | - ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន |
| **៣. ការអប់រំគ្រូបង្រៀន** | - កំណត់ស្តង់ដាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន<br>- អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | - ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន |
| **៤. អត្តសញ្ញាណ និងការអភិវឌ្ឍគ្រូបង្រៀន** | - ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន<br>- លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន<br>- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ | - ការគ្រប់គ្រង និងការបង្កើតគន្លងអាជីពគ្រូបង្រៀន<br>- ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន |

## ១.២. ស្ថានភាព និងបញ្ហាអាទិភាព

ចក្ខុវិស័យការអប់រំកម្ពុជា គឺបង្កើតសង្គមពុទ្ធិដែលមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញ គំនិតច្នៃប្រឌិត នវានុវត្តន៍ សហគ្រិនភាព និងមានសីលធម៌ខ្ពស់។ ផែនទីបង្ហាញផ្លូវឆ្នាំ២០៣០ របស់ប្រទេសកម្ពុជាបានទទួលស្គាល់ថា «ការអប់រំប្រកបដោយគុណភាព» ជាមធ្យោបាយចម្បងក្នុងការអភិវឌ្ឍធនធានមនុស្សដ៏រឹងមាំសម្រាប់ប្រទេសកម្ពុជា ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ លើសពីនេះទៀត ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ទទួលស្គាល់ពីសារៈសំខាន់នៃគ្រូបង្រៀនសម្រាប់ការអប់រំប្រកបដោយគុណភាព និងត្រូវ

បានរៀបចំឡើងដើម្បីអនុវត្តកំណែទម្រង់អប់រំ និងជាមូលដ្ឋានដ៏រឹងមាំមួយសម្រាប់ការអប់រំនៅឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់។

គោលដៅស្នូលនៃកំណែទម្រង់អប់រំ គឺធានាថាកុមារ «សិក្សា» នៅក្នុងសាលារៀន និងទទួលបានបំណិន និងសមត្ថភាពចាំបាច់សម្រាប់ការអភិវឌ្ឍធនធានមនុស្សដ៏រឹងមាំសម្រាប់ប្រទេសជាតិ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យថ្មីៗបង្ហាញថា កុមារជាច្រើននៅក្នុងប្រទេសកម្ពុជា មិនទាន់ទទួលបានការសិក្សាពេញលេញ។ ទិន្នន័យពីកម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ (PISA-D) ឆ្នាំ២០១៩ បានបង្ហាញថា មានតែ ៨% នៃកុមារអាយុ១៥ឆ្នាំ ដែលមានចំណេះដឹងអប្បបរមាលើអំណាន និង ១០% លើគណិតវិទ្យា។ លើសពីនេះទៀត លទ្ធផលពីការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ (NLA) សិស្សថ្នាក់ទី៦ ឆ្នាំ២០២១ បានបង្ហាញថាសមិទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៦ គឺមានតែ ៥៦% លើអំណាន និង ២៦% លើគណិតវិទ្យា។

នៅឆ្នាំ២០២១ ប្រទេសកម្ពុជាមានគ្រូបង្រៀនចំនួន ៦៤.៤៦% ដែលមិនមានសញ្ញាបត្របរិញ្ញាបត្រ ហើយប្រហែលជា ១ ភាគ ៤ នៃគ្រូបង្រៀនបឋមសិក្សា និងជិតពាក់កណ្តាលនៃគ្រូបង្រៀនមធ្យមសិក្សាមិនមានគុណវុឌ្ឍិស្របតាមស្តង់ដាគ្រូបង្រៀន[1]។ សម្រាប់គ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន២០% និងគ្រូឧទ្ទេសនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ១៣% ពុំមានសញ្ញាបត្របរិញ្ញាបត្រ [2]។ បន្ថែមលើនេះ កម្មវិធីអប់រំគ្រូបង្រៀនត្រូវធ្វើបច្ចុប្បន្នកម្មឱ្យស្របនឹងការអប់រំសតវត្សរ៍ទី២១។ គ្រូបង្រៀនពុំមានឱកាសគ្រប់គ្រាន់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីបង្កើនបំណិនគរុកោសល្យ និងគុណវុឌ្ឍិសិក្សា។

គុណភាពគ្រូបង្រៀន ជាកត្តាសំខាន់បំផុតនៅកម្រិតសាលារៀន ដែលមានឥទ្ធិពលលើសមិទ្ធផលសិក្សារបស់សិស្ស។ ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់សារៈសំខាន់នៃគុណភាពគ្រូបង្រៀន និងកំណត់កំណែទម្រង់គ្រូបង្រៀន ជាអាទិភាពយុទ្ធសាស្រ្តចម្បងសម្រាប់វិស័យអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំនាពេលបច្ចុប្បន្ន និងអនាគត។ ក្រសួងអប់រំ យុវជន និងកីឡា ក៏ទទួលស្គាល់ពីសារៈសំខាន់នៃការបង្កើតលក្ខខណ្ឌនានា ដែលអាចផ្តល់លទ្ធភាពដល់គ្រូបង្រៀនទទួលបានសិទ្ធិអំណាច និងការគាំទ្រដើម្បីផ្តល់នូវការអប់រំប្រកបដោយគុណភាពនៅក្នុងសាលារៀន និងធ្វើឱ្យគ្រូបង្រៀនកាន់តែមានទឹកចិត្តខ្ពស់ក្នុងការប្រកបការងារ។ ដូច្នេះ ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ បានផ្តោតលើយុទ្ធសាស្រ្តក្នុងការដោះស្រាយបញ្ហាអភិវឌ្ឍគ្រូបង្រៀនដែលមានលក្ខណៈរួមគ្រប់ជ្រុងជ្រោយ។

## ២. យុទ្ធសាស្រ្តទាំង៤នៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ និងយុទ្ធសាស្រ្តទាំង៩ នៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣

### ២.១. យុទ្ធសាស្រ្តទាំង៤

យុទ្ធសាស្រ្តទាំង៤ ត្រូវបានគាំទ្រដោយគោលការណ៍ និងការអនុវត្តបរិវត្តកម្មការអប់រំ ការធានាគុណភាពប្រកបដោយចីរភាព និងការអប់រំឌីជីថល។

---

[1] ក្រសួងអប់រំ យុវជន និងកីឡា (២០២២) ស្ថិតិ និងសូចនាករអប់រំ មត្តេយ្យសិក្សា និងសាលារៀនចំណេះទូទៅសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ២០២១/២០២២។ ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា។

[2] ស្ថិតិបុគ្គលិកអប់រំនៅគ្រឹះស្ថានអប់រំគ្រូបង្រៀនឆ្នាំ២០២១-២០២២ (នា.បវ)។

**យុទ្ធសាស្ត្រទី១៖ ការគ្រប់គ្រងគ្រូបង្រៀន** ផ្តោតលើការអនុវត្តការគ្រប់គ្រងគ្រូបង្រៀនដើម្បីធានាថាគោលនយោបាយ និងផែនការអប់រំត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព។ ដូច្នេះការវិនិយោគលើការអប់រំគឺជាការផ្លាស់ប្តូរជីវិតរបស់អ្នកសិក្សា និងអនាគតនៃសង្គម។ ការណ៍នេះតម្រូវឱ្យមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំនៃផលជះនៃការវិនិយោគលើវិស័យអប់រំដើម្បីធានាថា ធនធានបានទៅដល់គោលដៅដែលបានគ្រោងទុក និងទទួលបានលទ្ធផលសិក្សាដូចដែលបានរំពឹងទុកក្នុងគោលនយោបាយអប់រំ។

**យុទ្ធសាស្ត្រទី២៖ បរិវត្តកម្មភាពជាអ្នកដឹកនាំ** ផ្តោតលើអ្នកដឹកនាំអប់រំ ដែលតាមរយៈការអនុវត្តប្រកបដោយនវានុវត្តន៍ និងបរិយាបន្នពង្រឹងស្វ័យភាព ពង្រីកនិងលើកកម្ពស់ចំណាប់អារម្មណ៍របស់បុគ្គលិកអប់រំ បង្កើតការយល់ដឹងនិងការទទួលយកនូវគោលបំណងនិងបេសកកម្មអប់រំ និងចេះលើកទឹកចិត្តបុគ្គលិក ឱ្យគិតពីផលប្រយោជន៍រួមជាធំ។ អ្នកដឹកនាំតាមបែបបរិវត្តកម្ម ត្រូវបានគាំទ្រតាមរយៈកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

**យុទ្ធសាស្ត្រទី៣៖ ការអប់រំគ្រូបង្រៀន** ផ្តោតលើការអប់រំគ្រូបង្រៀនសតវត្សទី២១ ដែលអភិវឌ្ឍសមត្ថភាពតាមរយៈកម្មវិធីអប់រំនិងសម្ភារៈសិក្សាប្រកបដោយបរិយាបន្ននិងមានលក្ខណៈឆ្លុះបញ្ចាំង លើកកម្ពស់សមភាពនិងការគោរពចំពោះភាពចម្រុះ ហើយត្រូវមានជម្រើសសិក្សាដែលឆ្លើយតបនឹងបរិបទ គរុកោសល្យ និងកម្មវិធីអប់រំបែបចម្រុះ។ មូលដ្ឋានគ្រឹះនៃការអប់រំគ្រូបង្រៀន គឺការរៀនពីការបង្រៀន ការរៀនពីការបង្រៀនតាមមុខវិជ្ជា និងរៀនដើម្បីក្លាយជាគ្រូបង្រៀន។ ការអប់រំគ្រូបង្រៀនអាចពង្រឹងដោយបន្សុំជាមួយនឹងភស្តុតាងនៃឧត្តមានុវត្តន៍ទាំងក្នុងតំបន់ និងអន្តរជាតិ។

**យុទ្ធសាស្ត្រទី៤៖ អត្តសញ្ញាណនិងការអភិវឌ្ឍគ្រូបង្រៀន** ផ្តោតលើការលើកកម្ពស់អត្តសញ្ញាណ គុណតម្លៃ និងវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀនត្រូវតែទទួលស្គាល់អត្តសញ្ញាណ និងវិជ្ជាជីវៈរបស់ខ្លួន ហើយអភិវឌ្ឍនៅក្នុងការប្រតិបត្តិផ្ទាល់ ដែលនឹងធ្វើឱ្យជីវភាព គុណតម្លៃវិជ្ជាជីវៈ ឋានៈវិជ្ជាជីវៈ និងឋានៈសង្គមមានភាពប្រសើរឡើង។ កម្មវិធីវិក្រឹតការគ្រូបង្រៀនត្រូវបញ្ចូលនៅក្នុងការអនុវត្តវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀនត្រូវមានសិទ្ធិអំណាចក្នុងការរៀបចំ បកស្រាយ និងគ្រប់គ្រងកម្មវិធីសិក្សា និងជ្រើសរើសខ្លឹមសារមេរៀននិងវិធីសាស្ត្របង្រៀនអាទិភាព។

យុទ្ធសាស្ត្រទាំង៤ ស្ថិតក្រោមគោលការណ៍ និងការអនុវត្តដូចខាងក្រោម៖

1. **បរិវត្តកម្មការអប់រំ៖** គោលនយោបាយស្តីពីគ្រូបង្រៀនដែលមានធនធានគាំទ្រគ្រប់គ្រាន់ និង ត្រូវបានអនុវត្តប្រកបដោយឆន្ទៈនយោបាយ និងជំនាញរដ្ឋបាល ជាការវិនិយោគដ៏ល្អបំផុតរបស់ប្រទេសមួយក្នុងការអប់រំ និងមានសារៈសំខាន់ក្នុងការប្រើប្រាស់ទស្សនៈគ្រូបង្រៀនដើម្បីឱ្យយល់កាន់តែច្បាស់ពីគោលនយោបាយ ដែលអាចនាំឱ្យមានការផ្លាស់ប្តូរយូរអង្វែង។
2. **ការធានាគុណភាពប្រកបដោយចីរភាព៖** រួមបញ្ចូលសមាសធាតុនៃការធានាគុណភាពពាក់ព័ន្ធនឹងការរាយការណ៍ ស្វ័យវាយតម្លៃ និងសូចនាករសមិទ្ធកម្មនិងការលើកកម្ពស់គុណភាពដែលផ្តោតលើការកែលម្អបទពិសោធន៍នៃការរៀន និងបង្រៀន។ ប្រព័ន្ធអប់រំទំនើបត្រូវមានតុល្យភាពរវាងតម្រូវការទាំងពីរនៃការធានាគុណភាព និងការលើកកម្ពស់គុណភាព តាមរយៈការធានាគុណភាពប្រកបដោយចីរភាព។
3. **ការអប់រំឌីជីថល៖** បច្ចេកវិទ្យា និងការរៀនតាមប្រព័ន្ធឌីជីថល បានផ្សារភ្ជាប់គ្នាទៅគ្រប់ផ្នែកនៃការបង្រៀន និងរៀន ដើម្បីអភិវឌ្ឍសមត្ថភាពឌីជីថលរបស់គ្រូបង្រៀន និងសិស្សឱ្យឆ្លើយតបទៅនឹងបរិវត្តកម្មការអប់រំសតវត្សទី២១។ ការអប់រំឌីជីថល ប្រើនូវបច្ចេកវិទ្យាឌីជីថល និងសម្ភារៈសិក្សាផ្សេងទៀតដើម្បី

ផ្តល់នូវបរិយាកាសសិក្សាដែលត្រូវបានរៀបចំឡើងយ៉ាងល្អ ប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល មានអន្តរកម្ម និងគាំទ្រដល់អ្នកសិក្សាគ្រប់រូប គ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

### ២.២. យុទ្ធសាស្ត្រទាំង៩នៃគោលនយោបាយស្តីពីគ្រូបង្រៀន

យុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ ត្រូវបានបញ្ចូលជាយុទ្ធសាស្ត្រចំនួន៤ ដូចដែលមានក្នុងតារាងខាងក្រោម។ តារាងខាងក្រោមនេះសង្ខេបគំនិតផ្តួចផ្តើមដែលផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ ។

| យុទ្ធសាស្ត្រ | យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ | យុទ្ធសាស្ត្ររងនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ |
|---|---|---|
| ការគ្រប់គ្រងគ្រូបង្រៀន | កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការ | 1. អភិវឌ្ឍក្របខណ្ឌគោលនយោបាយថ្មីដើម្បីលើកកម្ពស់គុណភាពគ្រូបង្រៀន<br>2. ពិនិត្យឡើងវិញ ឬពង្រឹងគោលនយោបាយដែលមានស្រាប់ដើម្បីលើកកម្ពស់គុណភាពគ្រូបង្រៀន |
| | ពង្រឹងយន្តការ ឬប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន | 3. ពង្រឹងយន្តការរៀបចំផែនការ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| | ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា | 4. អនុវត្តគោលនយោបាយកំណែទម្រង់គ្រូបង្រៀនសំខាន់ៗ រួមទាំងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន<br>5. ពង្រឹងមូលដ្ឋានទិន្នន័យសម្រាប់ការធ្វើផែនការ និងការគ្រប់គ្រងការអភិវឌ្ឍគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព |
| បរិវត្តកម្មភាពជាអ្នកដឹកនាំ | ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន | 6. ពង្រឹង ឬអភិវឌ្ឍបំណិនភាពជាអ្នកដឹកនាំដល់នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀន<br>7. ពង្រឹងប្រសិទ្ធភាពនៃការដឹកនាំគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬសាលារៀនតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (អវប)<br>8. ពង្រឹងប្រសិទ្ធភាព ភាពជាអ្នកដឹកនាំសាលារៀនតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ |

| យុទ្ធសាស្ត្រ | យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ | យុទ្ធសាស្ត្ររងនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ |
|---|---|---|
| | | 9. ពង្រឹងប្រព័ន្ធគាំទ្រប្រឹក្សាគរុកោសល្យដល់នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀន<br>10. ពង្រឹងភាពជាដៃគូជាមួយមាតាបិតាសិស្ស និងសហគមន៍ |
| ការអប់រំគ្រូបង្រៀន | អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 11. បង្កើតវិទ្យាស្ថានគរុកោសល្យបន្ថែម<br>12. លើកកម្ពស់បរិយាកាសបង្រៀន និងរៀននៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន រួមទាំងវិទ្យាស្ថានជាតិអប់រំពិសេស<br>13. ពង្រឹងទំនាក់ទំនងរវាងគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលាអនុវត្តន៍ |
| | កំណត់ស្តង់ដាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន | 14. ដំឡើងគុណវុឌ្ឍិ និងអភិវឌ្ឍបំណិនវិជ្ជាជីវៈគ្រូឧទ្ទេស<br>15. ធ្វើកំណែទម្រង់កម្មវិធីអប់រំគ្រូបង្រៀន |
| អត្តសញ្ញាណនិងការអភិវឌ្ឍគ្រូបង្រៀន | ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន | 16. លើកកម្ពស់ ឬបង្កើតស្ថានភាពដែលអំណោយផលដល់គ្រូបង្រៀន |
| | លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន | 17. បង្កើត ឬពង្រឹងយន្តការដែលមានស្រាប់ដើម្បីលើកទឹកចិត្ត ទទួលស្គាល់ និងគាំទ្រគ្រូបង្រៀន<br>18. លើកកម្ពស់ប្រព័ន្ធឬយន្តការគាំទ្រគ្រូបង្រៀន និងគ្រូឧទ្ទេស |
| | អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ | 19. ផ្តល់ឱកាសក្នុងការអភិវឌ្ឍអាជីពដល់គ្រូបង្រៀន រួមទាំងគ្រូបង្រៀនជាប់កិច្ចសន្យា<br>20. ពង្រឹងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន |

## ៣. តារាងផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | *ទិន្នន័យដើមគ្រា ២០២៣* | *២០២៤* | *២០២៥* | *២០២៦* | *២០២៧* | *២០២៨* | *២០២៩* | *២០៣០* | | |
| **យុទ្ធសាស្ត្រទី១៖ ការគ្រប់គ្រងគ្រូបង្រៀន** | | | | | | | | | | | | |
| **យុទ្ធសាស្ត្ររង ១.១. អភិវឌ្ឍក្របខណ្ឌគោលនយោបាយថ្មីដើម្បីលើកកម្ពស់គុណភាពគ្រូបង្រៀន** *(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ)* | | | | | | | | | | | | |
| ១.១.១. អភិវឌ្ឍឬដាក់ឱ្យប្រើប្រាស់គោលនយោបាយថ្មីៗដើម្បីគាំទ្រដល់ការលើកកម្ពស់គុណភាពគ្រូបង្រៀន | ១.១.១.១. អភិវឌ្ឍគោលការណ៍ណែនាំដើម្បីគាំទ្រដល់ការទទួលស្គាល់ការសិក្សាពីមុន និង/ឬបទពិសោធន៍វិជ្ជាជីវៈដើម្បីផ្ទេរក្រេឌីតរវាងកម្មវិធីអប់រំគ្រូបង្រៀន | - គោលនយោបាយការទទួលស្គាល់ការសិក្សាពីមុនត្រូវបានអភិវឌ្ឍ និងអនុវត្តនៅគ្រឹះស្ថានអប់រំគ្រូបង្រៀន | ប្រកាសលេខ ១៨៧០ ឆ្នាំ២០១៩ ស្ដីពីការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនទៅកម្រិតបរិញ្ញាបត្រវិជ្ជាជីវៈគ្រូបង្រៀន | គោលការណ៍ណែនាំត្រូវបានព្រាង | គោលការណ៍ណែនាំត្រូវបានអនុវត្តសាកល្បង | គោលការណ៍ណែនាំត្រូវបានអនុវត្តសាកល្បង | គោលការណ៍ណែនាំត្រូវបានកែលម្អផ្អែកលើការរកឃើញពីការអនុវត្តសាកល្បង និង អនុម័ត | អនុវត្តនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន | អនុវត្តនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន | អនុវត្តនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន | នា.បល នា.បវ គអគ គទក នា.នត | ៨៧,០០០ |
| | ១.១.១.២. ដាក់ឱ្យប្រើប្រាស់ «អាជ្ញាប័ណ្ណវិជ្ជាជីវៈគ្រូបង្រៀន» ដល់និស្សិតបញ្ចប់ការសិក្សាពីគ្រឹះស្ថានអប់រំគ្រូបង្រៀនដែលបានទទួលស្គាល់តាមស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀនដើម្បីបំពេញបន្ថែមនូវ | - គោលនយោបាយស្តីពីអាជ្ញាប័ណ្ណគ្រូបង្រៀននិងបទប្បញ្ញត្តិត្រូវបានអភិវឌ្ឍ | គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | គោលនយោបាយ និង បទប្បញ្ញត្តិស្ដីពីអាជ្ញាប័ណ្ណបង្រៀនវិជ្ជាជីវៈ ត្រូវបានព្រាង | គោលនយោបាយ និង បទប្បញ្ញត្តិស្ដីពីអាជ្ញាប័ណ្ណបង្រៀនវិជ្ជាជីវៈ ត្រូវបានអនុម័តនិងអនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | នា.បវ នា.គប នា.នត នា.បល គទក | ៤១,២០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | គោលការណ៍ណែនាំនៃការពង្រាយគ្រូបង្រៀន | - ចំនួននិស្សិតបញ្ចប់ការសិក្សាដែលទទួលបានអាជ្ញាប័ណ្ណវិជ្ជាជីវៈគ្រូបង្រៀន (បែងចែកតាមយេនឌ័រ ពិការភាព ជនជាតិដើមភាគតិច) | ថ្មី | | សគមម ៣០នាក់ វគភ ០នាក់ វគប ០នាក់ វជអ ៦០ នាក់ | សគមម ១០០នាក់ វគភ ០នាក់ វគប ០នាក់ វជអ ៩០០នាក់ | សគមម ១៥០នាក់ វគភ ៣០នាក់ វគប ៣០នាក់ វជអ ១៤០០នាក់ | សគមម ២០០នាក់ វគភ ២១៧០នាក់ វគប ៥១០នាក់ វជអ ១៩០០នាក់ | សគមម ២៥០នាក់ វគភ ៤៣៤០នាក់ វគប ១០២០នាក់ វជអ ២៤០០នាក់ | សគមម ៣០០នាក់ វគភ ៦៥១០នាក់ វគប ១៥៣០នាក់ វជអ ២៩០០នាក់ | នា.បវ គអគ នា.បល | គអគ នឹងរកប្រាក់ចំណូល |
| **យុទ្ធសាស្ត្ររង ១.២. ពិនិត្យឡើងវិញ ឬពង្រឹងនូវគោលនយោបាយដែលមានស្រាប់ដើម្បីលើកកម្ពស់គុណភាពគ្រូបង្រៀន** ***(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ)*** | | | | | | | | | | | | |
| ១.២.១. ពិនិត្យឡើងវិញ ឬលើកកម្ពស់គោលនយោបាយដែលមានស្រាប់ដើម្បីអភិវឌ្ឍគ្រូបង្រៀនសតវត្សទី២១ | ១.២.១.១. ពិនិត្យឡើងវិញ និងកែលម្អគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ឱ្យស្របជាមួយ បរិវត្តកម្មការអប់រំ | - គោលនយោបាយគ្រូបង្រៀនត្រូវបានពិនិត្យឡើងវិញ និងកែលម្អដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ | គោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ | គោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ត្រូវបានពិនិត្យឡើងវិញ និងកែលម្អ | គោលនយោបាយគ្រូបង្រៀនឆ្នាំ២០២៥ត្រូវបានអនុម័ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | នា.គប នា.បល នា.បវ | ២០០,០០០ |
| | ១.២.១.២. ពិនិត្យឡើងវិញ ឬកែលម្អ និងអនុវត្តគោលនយោបាយពង្រាយគ្រូបង្រៀន និងពង្រាយគ្រូ | - គោលនយោបាយពង្រាយគ្រូបង្រៀនត្រូវបានកែលម្អដោយមានការចូលរួមពី | -អនុក្រឹត្យលេខ ១០២ (ឆ្នាំ២០០២) | | គោលនយោបាយត្រូវបានកែលម្អ | អនុវត្តសាកល្បង | អនុវត្តសាកល្បង | ពិនិត្យឡើងវិញ | អនុវត្ត | អនុវត្ត | នា.បល នា.គប នា.បវ | ៧០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | បង្រៀនឡើងវិញ ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀននៅសាលារៀនតាមជនបទ និងការលើសគ្រូបង្រៀននៅសាលារៀនក្នុងទីក្រុង | អ្នកពាក់ព័ន្ធសំខាន់ៗ និងត្រូវបានអនុវត្ត | -សេចក្ដីណែនាំ លេខ ៣៦៣២ (ឆ្នាំ២០០៥)<br>-សេចក្ដីណែនាំ លេខ ៥៣ (ឆ្នាំ២០១៩) | | និងអនុវត្តសាកល្បង | | | | | | | |
| | ១.២.១.៣. ពិនិត្យឡើងវិញ ឬកែលម្អគោលនយោបាយស្ដីពីម៉ោងបង្រៀនដើម្បីផ្លាស់ប្ដូរទៅការសិក្សាពេញមួយថ្ងៃ | - គោលនយោបាយត្រូវបានកែលម្អដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ និងត្រូវបានអនុវត្ត | គ្មាន | គោលនយោបាយត្រូវបានពិនិត្យឡើងវិញ | គោលនយោបាយត្រូវបានកែលម្អ | | អនុវត្តសាកល្បងនៅ៥ខេត្ត | អនុវត្តសាកល្បងនៅ១០ខេត្ត | អនុវត្តសាកល្បងនៅ១៥ខេត្ត | អនុវត្តសាកល្បងនៅ២៥រាជធានីខេត្ត | នា.គប<br>នា.បល<br>នា.អកត<br>នា.បស<br>នា.មចទ<br>នា.អកស<br>នា.បវ<br>នា.ធគអ | ១៥០,០០០ (សម្រាប់រៀបចំគោលនយោបាយ) |
| | ១.២.១.៤. ពិនិត្យឡើងវិញ និងអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឱ្យស្របនឹងបរិវត្តកម្មការអប់រំ និងតម្រូវការសតវត្សរ៍ទី២១ | - ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានពិនិត្យឡើងវិញនិងកែលម្អដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ឆ្នាំ២០១៦ | | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានពិនិត្យឡើងវិញ | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានកែលម្អ និងអនុម័ត | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានអនុវត្ត | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានអនុវត្ត | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានអនុវត្ត | ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានអនុវត្តទូទាំងប្រទេស | នា.បវ<br>គអគ<br>នា.គប<br>នា.បល | ១០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | - ចំនួនគ្រូបង្រៀនដែលបានទទួលការតម្រង់ទិសស្តីពីស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនដែលបានកែលម្អ (បែងចែកតាមយេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | ថ្មី | | | ២,០០០ | ៤,០០០ | ៦,០០០ | ៨,០០០ | ១០,០០០ | នា.បវ<br>នា.បល | ១,២០០,០០០ |
| | | - សិក្ខាសាលាចែករំលែកឧត្តមានុវត្តន៍ និងមេរៀនល្អៗត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ | ថ្មី | | | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | នា.បវ<br>នា.បល | ១៥០,០០០ |
| **យុទ្ធសាស្ត្ររង ១.៣. ពង្រឹងយន្តការរៀបចំផែនការ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ**<br>*(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ពង្រឹងយន្តការ ឬប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន)* | | | | | | | | | | | | |
| ១.៣.១. ពង្រឹងយន្តការប្រមូលទិន្នន័យដើម្បីរៀបចំផែនការ ការត្រួតពិនិត្យតាមដាន និងគោលនយោបាយ | ១.៣.១.១. ធ្វើការស្ទង់មតិប្រចាំឆ្នាំស្តីពីគ្រូបង្រៀននិងវិជ្ជាជីវៈគ្រូបង្រៀនដើម្បីប្រមូលជាគុចូលទាក់ទងនឹងគោលនយោបាយ លក្ខខណ្ឌការលើកទឹកចិត្ត ការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | - ចំនួនការស្ទង់មតិដែលបានបញ្ចប់ និងរបាយការណ៍ នៅថ្នាក់ជាតិ (អ្នកចូលរួមស្ទង់មតិបែងចែកតាមយេនឌ័រ ពិការភាព | ១ | | | ៣ | | ៥ | | ៧ | នា.បល<br>នា.គប | ២៨០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | ការអភិវឌ្ឍអាជីព និងបញ្ហាពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយគ្រូបង្រៀន | និងជនជាតិដើមភាគតិច) | | | | | | | | | | |
| | ១.៣.១.២. ធ្វើការស្រាវជ្រាវពីគ្រូបង្រៀន និងវិជ្ជាជីវៈបង្រៀនជាប្រចាំ ដើម្បីកែលម្អ ឬធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងកម្មវិធីដែលមានស្រាប់ | - ផែនការស្រាវជ្រាវត្រូវបានអភិវឌ្ឍដោយមានធាតុចូលពីគ្រូបង្រៀន និងធ្វើប្រចាំឆមាស និងរបាយការណ៍ត្រូវបានរៀបចំ និងចែករំលែក | គ្មាន | ផែនការស្រាវជ្រាវត្រូវបានអភិវឌ្ឍ លើប្រធានបទផ្សេងៗទាក់ទងនឹងគ្រូបង្រៀន | | ការសិក្សាចំនួន៣ | | ការសិក្សាចំនួន៥ | | ការសិក្សាចំនួន៧ | នា.គប<br>នា.បល | ២៦០,០០០ |
| **យុទ្ធសាស្ត្ររង ១.៤. អនុវត្តគោលនយោបាយកំណែទម្រង់គ្រូបង្រៀនសំខាន់ៗ រួមទាំងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន**<br>*(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា)* | | | | | | | | | | | | |
| ១.៤.១. អនុវត្តនូវគោលនយោបាយ និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនដែលបានកែលម្អ | ១.៤.១.១. អនុវត្តគន្លងអាជីពគ្រូបង្រៀន ស្របនឹងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីគាំទ្រដល់វឌ្ឍនភាពអាជីពផ្អែកលើគុណសម្បត្តិ | - ចំនួនគ្រូបង្រៀនដែលដែលត្រូវបានដំឡើងឋានៈវិជ្ជាជីវៈនៅក្នុងគន្លងអាជីពគ្រូបង្រៀន (បែងចែកតាម យេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | ១០១ | | | ៣០០ | | ៥០០ | | ៨០០ | នា.បល<br>នា.បវ | ២០០,០០០ |
| | | - ចំនួនអ្នកចូលរួមដែលបានកត់ត្រានិង | ៤,០០០ | | | ២៤,០០០ | | ៣២,០០០ | | ៥០,០០០ | នា.បល | - |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | ដំឡើងឋានៈវិជ្ជាជីវៈផ្អែកលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់គុណភាព (បែងចែកតាមយេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | | | | | | | | | | |
| | ១.៤.១.២. អភិវឌ្ឍនិងអនុវត្តការគ្រប់គ្រងការបំពេញការងាររបស់នាយកសាលា និងគ្រូបង្រៀនផ្អែកលើស្តង់ដានាយកសាលា និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដែលបានកែលម្អ | - គោលការណ៍ណែនាំ និងឧបករណ៍នៃប្រព័ន្ធគ្រប់គ្រងការបំពេញការងារត្រូវបានអភិវឌ្ឍដោយមានជាតុចូលពីនាយកសាលា និងគ្រូបង្រៀន ស្របតាមស្តង់ដានាយកសាលា និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលបានកែលម្អ និងត្រូវបានអនុវត្ត | -ឧបករណ៍វាយតម្លៃគន្លងអាជីពគ្រូបង្រៀន<br>-គោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងការបំពេញការងារ | គោលការណ៍ណែនាំ និងឧបករណ៍ត្រូវបានអភិវឌ្ឍ | គោលការណ៍ណែនាំ និងឧបករណ៍ត្រូវបានអនុវត្តសាកល្បង | គោលការណ៍ណែនាំ និងឧបករណ៍ត្រូវបានកែលម្អចុងក្រោយ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | នា.បល<br>នា.បវ | ១០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | - ចំនួននាយកសាលារៀន និងគ្រូបង្រៀនដែលបានបំពេញស្តង់ដា (បែងចែកតាមេយនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | 0 | | | ៥០ | | ២០០ | | ៥០០ | នា.បល<br>នា.គប | ២០០,000 |
| **យុទ្ធសាស្ត្ររង ១.៥. ពង្រឹងមូលដ្ឋានទិន្នន័យសម្រាប់ការធ្វើផែនការ និងការគ្រប់គ្រងការអភិវឌ្ឍគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព**<br>***(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា)*** | | | | | | | | | | | | |
| ១.៥.១. អភិវឌ្ឍប្រព័ន្ធព័ត៌មាននៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀនស្តីពីគ្រូបង្រៀន គ្រូឧទ្ទេស និងគរុសិស្ស គរុនិស្សិត | ១.៥.១.១. ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីឱ្យគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀន (រួមទាំងប្រវត្តិរូបគ្រូបង្រៀន គ្រូឧទ្ទេស និងគរុសិស្ស គរុនិស្សិត) ដើម្បីបង្កើតនូវព័ត៌មានឌីជីថលសំខាន់ៗនៅកម្រិតគ្រឹះស្ថាន | - ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានកែលម្អ និងអាចមានអន្តរកម្មជាមួយប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្សេងទៀតដើម្បីអាចទាញយកព័ត៌មានឌីជីថលនៅកម្រិតគ្រឹះស្ថានអប់រំគ្រូបង្រៀន | ម៉ូឌុលសម្រាប់គរុសិស្ស គរុនិស្សិតក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានធ្វើបច្ចុប្បន្នភាពនិងអនុវត្ត | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានកែលម្អនិងអនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | នា.បល<br>នា.បវព<br>នា.ពអ | ៦០០,000 |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | - % គ្រឹះស្ថានអប់រំគ្រូបង្រៀនប្រើប្រាស់ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស និងរៀបចំរបាយការណ៍ | ២០% | ៥០% | ៩០% | ១០០% | | | | | នា.បល<br>នា.បវព<br>នា.ពអ | ៥០០,០០០ |
| | | - % សាលារៀនប្រើប្រាស់ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស តាមកម្រិត | ១០% | ៣០% | ៥០% | ៦០% | ៧០% | ៨០% | ៩០% | ១០០% | នា.បល<br>នា.ពអ | ១,០០០,០០០ |
| ១.៥.២. ពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំក្នុងការរៀបចំផែនការ និងគ្រប់គ្រងធនធានមនុស្សដោយផ្អែកលើភស្តុតាង និងទិន្នន័យ | ១.៥.២.១. ពង្រឹងសមត្ថភាពអ្នកដឹកនាំអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើការធ្វើផែនការ និងការត្រួតពិនិត្យតាមដានផ្អែកលើភស្តុតាង | - វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការនិងការត្រួតពិនិត្យ តាមដានផ្អែកលើ ភស្តុតាងត្រូវបានអភិវឌ្ឍ | -និយាមបុគ្គលិក<br>-ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស | | វគ្គបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍ | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | នា.បល<br>នា.ផក | ២២០,០០០ |
| | | - វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការអប់រំសម្រាប់គណៈគ្រប់គ្រង | គ្មាន | | វគ្គបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍ | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | វគ្គបណ្តុះបណ្តាលត្រូវបានអនុវត្ត | នា.ផក | ២២០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | គ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀនត្រូវបានអភិវឌ្ឍ | | | | | | | | | | |
| | | - % គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀនដែលបានបញ្ចប់/ទទួលបានក្រេឌីតវគ្គបណ្តុះបណ្តាល (ស្ត្រី ៣០% និងបែងចែកតាមពិការភាព និងជនជាតិដើមភាគតិច) | 0 | | | ៥0% | | ១00% | | | នា.បល<br>នា.ផក | ២00,000 |
| | | - % គណៈគ្រប់គ្រងសាលារៀនដែលបានបញ្ចប់/ទទួលបានក្រេឌីតវគ្គបណ្តុះបណ្តាល (ស្ត្រី ៣0% និងបែងចែកតាមពិការភាព និងជនជាតិ) | 0 | | | ១0% | ២0% | ៣0% | ៤0% | ៥0% | នា.បល<br>នា.ផក | ១0,000,000 |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | ១.៥.២.២. ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ដើម្បីគ្រប់គ្រងការវាយតម្លៃការបំពេញការងារ តម្រូវការ/ការផ្គត់ផ្គង់គ្រូបង្រៀន ការផ្លាស់ប្តូរទីកន្លែងការងារ ការសុំឈប់សម្រាកប្រចាំឆ្នាំ ជាដើម | - ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ត្រូវបានពិនិត្យឡើងវិញ និងកែលម្អដោយមានការពិគ្រោះយោបល់ជាមួយគ្រូបង្រៀន និងគ្រូឧទ្ទេស | -ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស<br>-កម្មវិធីធនធានមនុស្ស និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានពិនិត្យឡើងវិញ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានអនុវត្តនិងបណ្តុះបណ្តាល | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានអនុវត្តនិងបណ្តុះបណ្តាល | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានអនុវត្តនិងបណ្តុះបណ្តាល | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានអនុវត្តនិងបណ្តុះបណ្តាល | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សត្រូវបានអនុវត្តនិងបណ្តុះបណ្តាល | នា.បល | ១,៣០០,០០០ |
| | | - % គ្រឹះស្ថានអប់រំគ្រូបង្រៀនដែលត្រូវបានបណ្តុះបណ្តាលនិងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស | ២០% | ៥០% | ៩០% | ១០០% | | | | | នា.បល | - |
| | | - % សាលារៀនដែលត្រូវបានបណ្តុះបណ្តាលនិងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស | ១០% | ៣០% | ៥០% | ៦០% | ៧០% | ៨០% | ៩០% | ១០០% | នា.បល | - |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| **យុទ្ធសាស្ត្រទី២៖ បរិវត្តកម្មភាពជាអ្នកដឹកនាំ** | | | | | | | | | | | | |
| យុទ្ធសាស្ត្ររង ២.១. ពង្រឹងឬអភិវឌ្ឍបំណិនភាពជាអ្នកដឹកនាំដល់នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀន *(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន)* | | | | | | | | | | | | |
| ២.១.១. បង្កើត និងអនុវត្ត កម្មវិធីភាពជាអ្នកដឹកនាំ កាតព្វកិច្ចដល់គណៈគ្រប់គ្រង គ្រឹះស្ថានអប់រំគ្រូបង្រៀន និង សាលារៀន | ២.១.១.១. ដាក់ឱ្យអនុវត្ត វគ្គបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំដល់ គណៈគ្រប់គ្រងគ្រឹះស្ថាន អប់រំគ្រូបង្រៀន និងសាលារៀន គ្រប់កម្រិត (មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា បឋមភូមិ និងមធ្យមសិក្សា ទុតិយភូមិ) ជាវគ្គសិក្សា កាតព្វកិច្ច សម្រាប់នាយក សាលារៀនថ្មីមុនពេលចូល កាន់តួនាទី | - កញ្ចប់បណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំ រួមទាំងសៀវភៅ ណែនាំការបណ្តុះ បណ្តាលគ្រូបង្គោល ត្រូវបានអភិវឌ្ឍ និង អនុវត្ត | កម្មវិធីបណ្តុះ បណ្តាល របស់ វជអ | កញ្ចប់វគ្គ សិក្សាត្រូវ បាន អភិវឌ្ឍ (សមាស ភាគចំនួន ៥ និងសូច នាករចំនួន ៧១) | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | វជអ វគ នា.បវ នា.បល | ១០០,០០០ |
| | | - ចំនួនគណៈគ្រប់គ្រង សាលារៀនថ្មីបាន ចូលរៀននិងបញ្ចប់វគ្គ បណ្តុះបណ្តាលភាព ជាអ្នកដឹកនាំ (ស្ត្រី ៣០% និងបែងចែក តាម ពិការភាព និង ជនជាតិដើមភាគ តិច) | ០ | ២៥០ | ៥០០ | ៧៥០ | ១,០០០ | ១,២៥០ | ១,៥០០ | ១,៧៥០ | វជអ វគ នា.បវ នា.បល | |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | - វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំត្រូវបានពិនិត្យឡើងវិញនិងកែលម្អរៀងរាល់ឆ្នាំដោយបញ្ចូលអនុសាសន៍និងឧត្តមានុវត្តន៍ពីអ្នកចូលរួម | | | | ពិនិត្យឡើងវិញលើកទី១ | ពិនិត្យឡើងវិញលើកទី២ | ពិនិត្យឡើងវិញលើកទី៣ | ពិនិត្យឡើងវិញលើកទី៤ | ពិនិត្យឡើងវិញលើកទី៤ | វជអ<br>វគ<br>នា.បវ<br>នា.បល | ២៥២,០០០ |
| | ២.១.១.២. ពិនិត្យឡើងវិញ ឬកែលម្អស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀនឱ្យស្របនឹងបំណិនសតវត្សរ៍ទី២១ និងបរិវត្តកម្មភាពជាអ្នកដឹកនាំ និងអនុវត្តនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀនទាំងអស់ | - ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀននិងស្តង់ដានាយកសាលារៀនត្រូវបានកែលម្អនិងអនុវត្ត | -ស្តង់ដានាយកសាលាឆ្នាំ២០១៧<br>-ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យឆ្នាំ២០១០ | ស្តង់ដានាយកសាលាត្រូវបានកែលម្អ | -ស្តង់ដានាយកសាលាដែលបានកែលម្អត្រូវបានផ្សព្វផ្សាយ<br>-ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀនត្រូវបានកែលម្អ | ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀននិងសាលារៀនដែលបានកែលម្អត្រូវបានផ្សព្វផ្សាយ | ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀននិងសាលារៀនដែលបានកែលម្អត្រូវបានផ្សព្វផ្សាយ | ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀននិងសាលារៀនដែលបានកែលម្អត្រូវបានផ្សព្វផ្សាយ | ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀននិងសាលារៀនដែលបានកែលម្អត្រូវបានផ្សព្វផ្សាយ | ស្តង់ដានាយកគ្រឹះស្ថានអប់រំគ្រូបង្រៀននិងសាលារៀនដែលបានកែលម្អត្រូវបានផ្សព្វផ្សាយ | នា.បវ<br>នា.បល<br>នា.ផក | ៤០០,០០០ |
| | | - % នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀនដែលបំពេញតាមស្តង់ដាដែលបានកែលម្អ | ថ្មី | | | | ៣០% | ៥០% | ៧៥% | ១០០% | នា.បវ<br>គអគ | ២០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | (បែងចែកតាមយេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | | | | | | | | | | |
| | | - % នាយកសាលារៀនដែលបំពេញតាមស្តង់ដាដែលបានកែលម្អ (បែងចែកតាមយេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | 0 | | ១០% | ១៥% | ២០% | ២៥% | ៣០% | ៣៥% | នា.បវ គអគ | ៦០០,០០០ |
| **យុទ្ធសាស្ត្ររង ២.២. ពង្រឹងប្រសិទ្ធភាពនៃការដឹកនាំគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬសាលារៀនតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** ***(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន)*** | | | | | | | | | | | | |
| ២.២.១. អភិវឌ្ឍ ឬអនុវត្តវគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬនាយកសាលាដោយផ្តោតលើប្រធានបទសំខាន់ៗដូចជាបំណិនសតវត្សរ៍ទី២១ ការគិតជាយុទ្ធសាស្ត្រ និងការគ្រប់គ្រងដែលឆ្លើយតបនឹងយេនឌ័រ និងពិការភាព | ២.២.១.១. អភិវឌ្ឍវគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈតាមបែបចម្រុះ និងតាមប្រព័ន្ធក្រេឌីតសម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀនដោយផ្អែកលើការវិភាគតម្រូវការ | - ចំនួនវគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមបែបចម្រុះត្រូវបានអភិវឌ្ឍ (៨) មានការទទួលស្គាល់ និងអនុវត្ត | វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងចំនួន ២ | វគ្គបណ្តុះបណ្តាលចំនួន៣ (១២៣) ត្រូវបានអភិវឌ្ឍ និងអនុវត្ត | វគ្គបណ្តុះបណ្តាលចំនួន៦ (៤ ៥ ៦) ត្រូវបានអភិវឌ្ឍ និងអនុវត្ត | វគ្គបណ្តុះបណ្តាលចំនួន៨ (៧ ៨) ត្រូវបានអភិវឌ្ឍ និងអនុវត្ត | | | | | នា.បវ នា.បល | ៦០០,០០០ |
| | | - % គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀនដែលបាន | 0 | | វគ្គ១-៣ (១០០%) | វគ្គ៤-៦ (១០០%) | វគ្គ៧-៨ (១០០%) | | | | នា.បវ នា.បល | ៩៧២,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | បញ្ចប់វគ្គនិងទទួលបានក្រេឌីត (យ៉ាងតិចមានស្ត្រី ៣០% និងបែងចែកតាមពិការភាព និងជនជាតិដើមភាគតិច) | | | | | | | | | | |
| | | - % គណៈគ្រប់គ្រងសាលារៀនដែលបានបញ្ចប់វគ្គនិងទទួលបានក្រេឌីត (យ៉ាងតិចមានស្ត្រី ៣០% និងបែងចែកតាមពិការភាព និងជនជាតិដើមភាគតិច) | 0 | | វគ្គ១-៣ (១0%) | វគ្គ១-៣ (២0%)<br>វគ្គ៤-៦ (១0%) | វគ្គ១-៣ (៣0%)<br>វគ្គ៤-៦ (២0%)<br>វគ្គ៧-៨ (១0%) | វគ្គ១-៣ (៤0%)<br>វគ្គ៤-៦ (៣0%)<br>វគ្គ៧-៨ (២0%) | វគ្គ១-៣ (៥0%)<br>វគ្គ៤-៦ (៤0%)<br>វគ្គ៧-៨ (៣0%) | វគ្គ១-៣ (៦0%)<br>វគ្គ៤-៦ (៥0%)<br>វគ្គ៧-៨ (៤0%) | នា.បវ<br>នា.បល | ៥៩,៦00,000 |
| | ២.២.១.២. អភិវឌ្ឍកញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន សម្រាប់នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន និងកែលម្អកញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងសាលារៀន និងអនុវត្ត | - កញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន សម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀនត្រូវបានអភិវឌ្ឍ | ថ្មី | កញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងតាមគអគ សម្រាប់គណៈគ្រប់គ្រង | | | | | | | នា.បវ<br>នា.បល | ១00,000 |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | | | គអគ ត្រូវបានអភិវឌ្ឍ | | | | | | | | |
| | | - កញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងសាលារៀនសម្រាប់នាយកសាលារៀនត្រូវបានកែលម្អ និងអនុវត្ត | កញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងសាលារៀនដែលបានធ្វើសុខដុមនីយកម្មឆ្នាំ២០១៩ | កញ្ចប់បណ្តុះបណ្តាលការគ្រប់គ្រងតាមសាលារៀនសម្រាប់នាយកសាលារៀនត្រូវបានកែលម្អ | | | | | | | នា.បវ<br>នា.បល | ១០០,០០០ |
| | | - % គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀនបានបញ្ចប់ដោយជោគជ័យ និងទទួលបានក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពីវគ្គបណ្តុះបណ្តាលការគ្រប់គ្រងតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន | ០ | | | ៥០% | ១០០% | | | | នា.បវ<br>នា.បល | ១៨០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | - % នាយកសាលារៀនបានបញ្ចប់ដោយជោគជ័យ និងទទួលបានក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពីវគ្គបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀនដែលបានកែលម្អ | ០ | | ១០% | ២០% | ៣០% | ៤០% | ៥០% | ៦០% | នា.បវ នា.បល | ១០,៧៥៦,៩៨០ |
| **យុទ្ធសាស្ត្ររង ២.៣. ពង្រឹងប្រសិទ្ធភាព ភាពជាអ្នកដឹកនាំសាលារៀនតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ** ***(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន)*** | | | | | | | | | | | | |
| ២.៣.១. ពង្រីក ឬលើកកម្ពស់សហគមន៍សិក្សាវិជ្ជាជីវៈដែលមានស្រាប់ដើម្បីពង្រឹងប្រសិទ្ធភាពសាលារៀន | ២.៣.១.១. ពង្រឹងតួនាទី និងភារៈកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀននៅតាមកម្រង និងថ្នាក់ជាតិ | - ចំនួនសហគមន៍សិក្សាវិជ្ជាជីវៈដែលដំណើរការនៅតាមកម្រង ឬថ្នាក់ស្រុកសម្រាប់ភាពជាអ្នកដឹកនាំនៅកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និង | គ្មាន | ១ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | ២ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | ៣ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | ៤ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | ៥ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | ៦ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | ៧ សហគមន៍សិក្សាវិជ្ជាជីវៈក្នុងមួយកម្រិតក្នុងមួយខេត្ត | នា.បវ នា.បល នា.អកត នា.បស នា.មចទ គអគ មន្ទីរ អយក ការិ. អយក | ៣,០០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | មធ្យមសិក្សាទុតិយភូមិ (យ៉ាងតិចមានស្ត្រី ៣០%) រួមទាំងផែនការសកម្មភាព និងរបាយការណ៍ប្រចាំឆ្នាំ | | ១០០ សហគមន៍ទូទាំងប្រទេស | ២០០ សហគមន៍ទូទាំងប្រទេស | ៣០០ សហគមន៍ទូទាំងប្រទេស | ៤០០ សហគមន៍ទូទាំងប្រទេស | ៥០០ សហគមន៍ទូទាំងប្រទេស | ៦០០ សហគមន៍ទូទាំងប្រទេស | ៧០០ សហគមន៍ទូទាំងប្រទេស | | |
| | ២.៣.១.២. រៀបចំសន្និសីទ ឬសិក្ខាសាលាថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរនិងចែករំលែកបទពិសោធន៍ភាពជាអ្នកដឹកនាំនៅតាមសាលារៀននិងគ្រឹះស្ថានអប់រំគ្រូបង្រៀនក្នុងបណ្តាញវិជ្ជាជីវៈ | - ចំនួនសន្និសីទដែលត្រូវបានរៀបចំនិងផ្សព្វផ្សាយជារៀងរាល់ឆ្នាំ | ០ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | ១ដង សម្រាប់រាជធានីខេត្តនីមួយៗ | មន្ទីរ អយក ការិ. អយក សាលារៀន | ៣,២៧៦,០០០ |
| | ២.៣.១.៣. រៀបចំឱ្យមានសន្និសីទ ឬសិក្ខាសាលានៅថ្នាក់ជាតិដើម្បីផ្លាស់ប្តូរនិងចែករំលែកបទពិសោធន៍ពីភាពជាអ្នកដឹកនាំនៅតាមសាលារៀននិងគ្រឹះស្ថានអប់រំគ្រូបង្រៀនក្នុងបណ្តាញវិជ្ជាជីវៈ | - ចំនួនសន្និសីទដែលត្រូវបានរៀបចំនិងផ្សព្វផ្សាយជារៀងរាល់ឆ្នាំ | ០ | ១ | ១ | ១ | ១ | ១ | ១ | ១ | អគ.អរ អគ.របគអគ | ២២៣,៥០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| **យុទ្ធសាស្ត្ររង ២.៤. ពង្រឹងប្រព័ន្ធគាំទ្រប្រឹក្សាគរុកោសល្យដល់នាយកគ្រឹះស្ថានអប់រំគ្រូបង្រៀន និងសាលារៀន** ***(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន)*** | | | | | | | | | | | | |
| ២.៤.១. អភិវឌ្ឍប្រព័ន្ធប្រឹក្សាគរុកោសល្យសម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រូបង្រៀន/សាលារៀន | ២.៤.១.១. បង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យសម្រាប់គណៈគ្រប់គ្រងសាលារៀន ដោយកំណត់គ្រូប្រឹក្សាគរុកោសល្យ (គ្រូប្រឹក្សាគរុកោសល្យ អ្នកជំនាញភាពជាអ្នកដឹកនាំរបស់ក្រសួង អយក គ្រូបង្គោល នាយកសាលាគំរូ និងបុគ្គលិកអប់រំពាក់ព័ន្ធផ្សេងទៀតដែលមានការទទួលស្គាល់) តាមរយៈការផ្តល់នូវកិច្ចសន្ទនាសកម្ម ការណែនាំ និងការគាំទ្រដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅតាមសាលារៀន | - កម្មវិធីប្រឹក្សាគរុកោសល្យ (សាលារៀន សាលាកម្រង ថ្នាក់ស្រុក និងថ្នាក់ជាតិ) ត្រូវបានអភិវឌ្ឍ និងអនុវត្ត | គ្មាន | កម្មវិធីប្រឹក្សាគរុកោសល្យសម្រាប់គណៈគ្រប់គ្រងគអគ និងសាលារៀនត្រូវបានអភិវឌ្ឍ | កម្មវិធីប្រឹក្សាគរុកោសល្យត្រូវបានអនុវត្តសាកល្បង | កម្មវិធីប្រឹក្សាគរុកោសល្យត្រូវបានអនុវត្តសាកល្បង | កម្មវិធីប្រឹក្សាគរុកោសល្យត្រូវបានពង្រីកវិសាលភាព | កម្មវិធីប្រឹក្សាគរុកោសល្យត្រូវបានពង្រីកវិសាលភាព | កម្មវិធីប្រឹក្សាគរុកោសល្យត្រូវបានពង្រីកវិសាលភាព | កម្មវិធីប្រឹក្សាគរុកោសល្យត្រូវបានពង្រីកវិសាលភាព | នា.បវ<br>នា.អកត<br>នា.បស<br>នា.មចទ | ៧០០,០០០ |
| | | - % អ្នកទទួលប្រឹក្សាគរុកោសល្យ និងអ្នកផ្តល់ប្រឹក្សាគរុកោសល្យនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន សាលារៀន និងសាលាកម្រង (យ៉ាងតិចមានស្ត្រី ៣០% និងបែងចែកតាមពិការភាព | គ្មាន | | | | គអគ ១០០%<br>សាលារៀន ២០% | សាលារៀន ៣០% | សាលារៀន ៤០% | សាលារៀន ៥០% | នា.បវ<br>នា.អកត<br>នា.បស<br>នា.មចទ | ៧០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | | និងជនជាតិដើមភាគតិច) | | | | | | | | | | |
| | ២.៤.១.២. បង្កើតវេទិកាអនឡាញប្រចាំឆ្នាំសម្រាប់គ្រូអ្នកផ្តល់ប្រឹក្សាគរុកោសល្យ និងអ្នកទទួលប្រឹក្សាគរុកោសល្យ ដើម្បីចែករំលែកបទពិសោធន៍ | - ចំនួនអ្នកផ្តល់ប្រឹក្សាគរុកោសល្យ និងអ្នកទទួលប្រឹក្សាគរុកោសល្យចូលរួមវេទិកាប្រចាំឆ្នាំដើម្បីចែករំលែកឧត្តមានុវត្តន៍ និងមេរៀនដែលបានរៀន (បែងចែកតាមយេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច) | គ្មាន | | | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | នា.បវ<br>នា.អកត<br>នា.បស<br>នា.មចទ | ២៥០,០០០ |
| **យុទ្ធសាស្ត្ររង ២.៥. ពង្រឹងភាពជាដៃគូជាមួយមាតាបិតាសិស្ស និងសហគមន៍**<br>***(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន)*** | | | | | | | | | | | | |
| ២.៥.១. បង្កើតសហគមន៍ដែលរឹងមាំ និងមានការចូលរួមពីមាតាបិតាសិស្ស | ២.៥.១.១. ពង្រឹងតួនាទីនិងភារៈកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីលើកកម្ពស់ការចូលរួមរបស់មាតាបិតាសិស្សក្នុងការចុះឈ្មោះចូលរៀនទាន់ពេល | - % សាលារៀនដែលមានគណៈកម្មការគ្រប់គ្រងសាលារៀនដំណើរការ បែងចែកតាមកម្រិត (មត្តេយ្យសិក្សា | ២០% | ៣០% | ៤០% | ៥០% | ៦០% | ៧០% | ៨០% | ១០០% | អគ.អរ<br>នា.មចទ<br>នា.បស<br>នា.អកត | ៧០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ទិន្នន័យដើមគ្រា ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | វេលានិងបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន និងការគាំទ្ររបស់គ្រួសារក្នុងការសិក្សារបស់កូនៗនៅផ្ទះ រួមទាំងកុមារដែលមានពិការភាព និងបញ្ហាអាទិភាពផ្សេងទៀត | បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ) និងសមាជិកបែងចែកតាមយេនឌ័រ ពិការភាព និងជនជាតិដើមភាគតិច | | | | | | | | | | |
| **យុទ្ធសាស្ត្រទី៣៖ ការអប់រំគ្រូបង្រៀន** | | | | | | | | | | | | |
| **យុទ្ធសាស្ត្ររង ៣.១. បង្កើតវិទ្យាស្ថានគរុកោសល្យបន្ថែម**<br>*(យុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣៖ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន)* | | | | | | | | | | | | |
| ៣.១.១. បង្កើតវិទ្យាស្ថានគរុកោសល្យបន្ថែម | ៣.១.១.១. ធ្វើការវាយតម្លៃវិទ្យាស្ថានគរុកោសល្យទាំងពីរដើម្បីកំណត់លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់សម្រាប់ការពង្រីកកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ | - ការវាយតម្លៃត្រូវបានរៀបចំ ហើយលទ្ធផលត្រូវបានប្រើប្រាស់ដើម្បីបង្កើតវិទ្យាស្ថានគរុកោសល្យថ្មី | ការវាយតម្លៃដោយនា. បវ និង JICA | ការវាយតម្លៃត្រូវបានរៀបចំ | | | | | | | នា.បវ វគ | ១០,៨០០ |
| | ៣.១.១.២. អភិវឌ្ឍផែនការយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់គ្រឹះស្ថានអប់រំគ្រូបង្រៀន រួមទាំងការចាកចេញពីកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ | - ផែនការយុទ្ធសាស្ត្រត្រូវបានអភិវឌ្ឍតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងគ្រឹះស្ថានអប់រំគ្រូបង្រៀន | គ្មាន | ផែនការយុទ្ធសាស្ត្រត្រូវបានអភិវឌ្ឍនិងអនុវត្ត | ផែនការយុទ្ធសាស្ត្រត្រូវបានអនុវត្ត | ផែនការយុទ្ធសាស្ត្រត្រូវបានអនុវត្ត | ផែនការយុទ្ធសាស្ត្រត្រូវបានអនុវត្ត | ផែនការយុទ្ធសាស្ត្រត្រូវបានអនុវត្ត | ផែនការយុទ្ធសាស្ត្រត្រូវបានអនុវត្ត | ផែនការយុទ្ធសាស្ត្រត្រូវបានអនុវត្ត | នា.បវ គអគ | ១០០,០០០ |

| សកម្មភាព | សកម្មភាពរង | សូចនាករ | ចំណុចដៅ (ចំនួន និងភាគរយ) | | | | | | | | អង្គភាពទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|---|---|---|---|---|---|---|
